# សុន្ទរកថា

ឯកឧត្តម **ប៉ា សុជាតិវង្ស** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តីព្រះរាជាណាចក្រកម្ពុជា និងជាអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ក្នុងឱកាសប្រារព្ធពិធីមីទ្ទីញអបអរសាទរ **ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក** ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ នៅវិទ្យាល័យបឹងត្របែក រាជធានីភ្នំពេញ

- សូមក្រាបថ្វាយបង្គំ សម្តេចព្រះមហាអរិយវង្ស **សៅរ៍ ចន្ទថុល្ល** ព្រះអនុគណខណ្ឌចំការមន និងជាព្រះចៅអធិការវត្តលង្កា និងព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!
- សូមគោរពឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** ទេសរដ្ឋមន្រ្តី រដ្ឋមន្រ្តីក្រសួងបរិស្ថាន
- សូមគោរពលោកជំទាវ **ទន់ សារ៉ឹម** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា
- សូមគោរពគណៈអធិបតី ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក សមាជិកា នៃអង្គមិទ្ទីញជាទីមេត្រី និងក្មួយៗសិស្សានុសិស្សទាំងអស់ជាទីស្រឡាញ់រាប់អាន!

ថ្ងៃនេះខ្ញុំមានសេចក្តីរីករាយយ៉ាងខ្លាំងក្រៃលែង ដែលមានឱកាសមកចូលរួមជាគណៈអធិបតីក្នុងពិធីមីទ្ទីញ អបអរសាទរទិវាបរិស្ថានជាតិ និងទិវាបរិស្ថានពិភពលោក០៥ មិថុនា២០១៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមទេសរដ្ឋមន្រ្តីក្រសួងបរិស្ថាន។ តាងនាម គណៈអភិបាលរាជធានីភ្នំពេញ និងក្នុងនាមមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋក្នុងទូទាំងរាជធានីភ្នំពេញ ខ្ញុំសូមសំដែងនូវគារវៈកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមានរបស់ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉េត** ទេសរដ្ឋមន្រ្តីរដ្ឋមន្រ្តីក្រសួងបរិស្ថាន និងលោកជំទាវ **ទន់ សារ៉ឹម** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឱកាសដ៏ថ្លៃថ្លានេះ។

**អង្គមិទ្ទីញជាទីមេត្រី**!

មុននេះអង្គពិធីទាំងមូលបានតាមដានស្តាប់ឯកឧត្តម **ស៊ុំ សូខុធ** អនុរដ្ឋលេខាធិការក្រសួងបរិស្ថានអាននូវសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្រ្តីនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កប់ដោយអត្ថន័យយ៉ាងជ្រាលជ្រៅ ក្រោមប្រធានបទរបស់ កម្មវិធីបរិស្ថានសហប្រជាជាតិ សំរាប់ឆ្នាំនេះ គឺៈ **ត្រូវពិចារណា ពេលបរិភោគ ដើម្បីសន្សំសំចៃធនធាន** ។ ដើម្បីចូលរួមក្នុងកិច្ចការពារបរិស្ថាន និងភពផែនដី តាមរយៈការកែប្រែទម្លាប់ មិនបង្កើតសំណល់ចំណីអាហារ សាររបស់ **សម្តេចតេជោ សែន** បានដាស់ស្មារតីដល់មនុស្សគ្រប់ជាតិសាសន៍លើពិភពលោក ដោយរាប់បញ្ចូលទាំងប្រជាពលរដ្ឋកម្ពុជាផងដែរ អោយបន្ត និងបង្កើនការសន្សំសំចៃធនធានដែលយើងបានដកហូតពីធម្មជាតិ ឬផលិតក្នុងបរិស្ថានធម្មជាតិ ឆ្លងកាត់តាមខ្សែសង្វាក់ផលិតកម្មនិងការកែច្នៃយ៉ាងច្រើន បង្កើតបានជាសំភារៈ និងស្បៀងអាហារសំរាប់ទ្រទ្រង់អាយុជីវិតរបស់មនុស្ស អោយបានជាអតិបរមា។

**ព្រះតេជគុណគ្រប់ព្រះអង្គ ជាទីសក្ការៈ**!

កាលពី១០ ឆ្នាំមុនរាជធានីភ្នំពេញមានប្រជាពលរដ្ឋ ប្រមាណ ១ លាននាក់ប៉ុណ្ណោះ បច្ចុប្បន្នមានប្រជាពលរដ្ឋជិត៣ លាននាក់ដោយគិតរួមទាំងអ្នកប្រកបមុខរបរនិងអ្នកទេសចរណ៍។ ផ្អែកតាមកំណើនប្រជាពលរដ្ឋ

បច្ចុប្បន្នរាជធានីភ្នំពេញ បានពង្រីកផ្ទៃដីរហូតដល់ ៦៧៨,៤៦ គម ²ដែលរួមផ្សំដោយតំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់លំនៅដ្ឋាន តំបន់កសិកម្ម តំបន់ទន្លេបឹងបួរ និងហេដ្ឋារចនាសម្ព័ន្ធ។

ក្នុងបណ្តាទីក្រុងតំបន់អាស៊ីក៏ដូចជាពិភពលោក តាម និន្នាការកើនឡើងឥតឈប់ឈរនៃអត្រាកំណើនរបស់មនុស្ស កំណើនបច្ចេកវិជ្ជា កំណើនផលិតកម្មឧស្សាហកម្ម កសិកម្ម និងកំណើនសេដ្ឋកិច្ច បញ្ហាបរិស្ថានមួយចំនួនតែងតែជួបប្រទះដូចជា ការកកស្ទះចរាចរ ការផ្គត់ផ្គង់និងគុណភាពចំណីអាហារ ក៏ដូចជាបញ្ហា សំរាមសំណល់រឹងទីក្រុង បានធ្វើ ឲ្យអ្នកដឹកនាំនិងអភិបាលកិច្ច ទីប្រជុំជន ទីក្រុងនានា ទាំងនោះ មានការយកចិត្តទុកដាក់ចាត់វិធានការគ្រប់គ្រងនិងចំណាយថវិកាយ៉ាងច្រើនដើម្បីឆ្លើយតប។ វិបត្តិនៃការគ្រប់គ្រងសំណល់រឹងសំរាមជាពិសេសការទុកដាក់សំណល់ចុងក្រោយ បានធ្វើ ឲ្យផ្ទៃដីក្នុងទីក្រុងដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ក្លាយជាទីលានទុកដាក់សំរាម រីករាលដាលកាន់តែធំទៅៗ បាត់បង់នូវកាលានុវត្តភាពលើការអភិវឌ្ឍន៍វិស័យចាំបាច់ផ្សេងទៀត ជាពិសេសប្រទេសកំពុងអភិវឌ្ឍ ន៍។ ជាងនេះទៅទៀត ទីលានសំរាមដែលផ្ទុកដោយសំណល់ចំណីអាហារនិងសំភារៈប្រើប្រាស់របស់មនុស្ស បានបំភាយចេញនូវឧស្ម័នផ្ទះកញ្ចក់ (ឧស្ម័នកាបូនិច និងឧស្ម័នមេតាន) ដល់បរិយាកាស បង្កលក្ខខណ្ឌដល់ការឡើងកំដៅផែនដីនិងបំរែបម្រួលអាកាសធាតុ ព្រមទាំងធ្វើអោយមាន ការបំពុលទឹក ការបំពុលដី និងក្លិនអសោចបានធ្វើ ឲ្យប៉ះពាល់ដល់សុខភាព និងគុណភាពបរិស្ថានយ៉ាងធ្ងន់ធ្ងរ ប្រសិនបើគ្មានវិធានការណ៍ ការពារជាមុនតាមបទដ្ឋានបច្ចេកទេសឲ្យទាន់ពេលវេលានោះទេ។

នៅព្រះរាជាណាចក្រកម្ពុជា ទោះបីជាការទុកដាក់សំណល់មិនទាន់មានបញ្ហាធ្ងន់ធ្ងរក៏ដោយ តាមរយៈការយកចិត្តទុកដាក់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល ការគ្រប់គ្រងសំណល់រឹងត្រូវបានទទួលនូវការយកចិត្តទុកដាក់ខ្ពស់ តាមរយៈការរៀបចំគោលនយោបាយ លិខិតបទដ្ឋាន រៀបចំយន្តការនិងរចនាសម្ព័ន្ធគ្រប់គ្រងពីថ្នាក់ជាតិរហូតដល់មូលដ្ឋាន។ ជាក់ស្តែងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់នូវអនុសាសន៍មួយចំនួនដូចជា **"មិនអនុញ្ញាតិឲ្យកម្ពុជាក្លាយជាទីលានចាក់សំរាមរបស់ប្រទេសដទៃ" "ត្រូវធ្វើយ៉ាងណាទប់ស្កាត់ឲ្យខាងតែបាននូវផលប៉ះពាល់ដល់សុខភាព និងគ្រោះមហន្តរាយទៅលើបរិស្ថាន ដែលកកើតឡើងពីសំណល់ប្រកបដោយគ្រោះថ្នាក់" "ត្រូវយកចិត្តទុកដាក់គ្រប់គ្រងសំណល់ថង់ប្លាស្ទិក ធ្វើយ៉ាងណាមិនឲ្យហោះហើររាយប៉ាយតាមទីសាធារណៈ នាមុនដំណាច់ឆ្នាំ ២០១៥។ល។**

ឆ្លៀតក្នុងឱកាសនេះដែរ តាងនាមប្រជាពលរដ្ឋ ក្នុងទូទាំងរាជធានីភ្នំពេញ ខ្ញុំសូមសំដែងនូវការកោតសសើរចំពោះ ការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រសួងបរិស្ថានគ្រប់លំដាប់ថ្នាក់ ដែលជាសេនាធិការដ៏មានប្រសិទ្ធិភាពរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តកិច្ចការពារបរិស្ថាន និងថែរក្សាធនធានធម្មជាតិជាង២០ឆ្នាំកន្លងមកនេះ។ ដូចគ្នានេះផងដែរក្រោមការចង្អុលបង្ហាញនិងដឹកនាំពីក្រសួងបរិស្ថាន ខ្ញុំព្រះករុណាខ្ញុំសូមកោតសសើរចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ មន្ទីរបរិស្ថានរាជធានីភ្នំពេញ ដែលតែងតែមានគំនិតផ្តើម និងសិល្បៈនៃការដឹកនាំរស់រវើក ជាសេនាធិការអោយសាលារាជធានីភ្នំពេញ សម្រេចបាននូវស្នាដៃធំៗ និងទទួលបាននូវជ័យលាភីគ្រប់គ្រងបរិស្ថានទីក្រុង ជាបន្តបន្ទាប់។

**គណៈអធិបតីជាទីគោរព**!

ស្របតាមប្រធានបទសំរាប់ឆ្នាំនេះ THINK.EAT.SAVE ឬប្រែថា **ត្រូវពិចារណា- ពេលបរិភោគ- ត្រូវសន្សំសំចៃ** គឺជាយុទ្ធនាការដ៏សំខាន់មួយប្រឆាំងទៅនឹងការខ្ជះខ្ជាយចំណីអាហារ -ការបង្កើនសំណល់និងកិច្ចការពារបរិស្ថាន។ ខ្ញុំយល់ឃើញថា ជាទូទៅ ប្រសិនបើអ្នកបរិភោគចំណីអាហារម្នាក់ អាចកំពប់ឬសល់

ចំណីអាហារមួយស្លាបព្រា ទូទាំងប្រទេសកម្ពុជាមានសំណល់អាហារជាង ១០លានស្លាបព្រាក្នុងមួយពេលពិសាអាហារ ឬអាចធ្វើអោយយើងមានអាហារជិត៣០លានស្លាបព្រា ឬប្រមាណជិត ៣០០ តោនក្នុងមួយថ្ងៃក្លាយជាសំណល់។ អាហារទាំងនោះបានមកពីការដកហូតធនធានធម្មជាតិ ការធ្វើពលកម្មផលិតនិងកែឆ្នៃការចំណាយធនធាននិងពេលវេលា ព្រមទាំងសេវាបំរើយ៉ាងច្រើនលើសលប់។

ទាក់ទងដល់ការគ្រប់គ្រងសំណល់ នៅរាជធានីភ្នំពេញនាអំឡុងឆ្នាំ២០០០បរិមាណសំរាមប្រចាំថ្ងៃមានប្រមាណ៦០០តោនប៉ុណ្ណោះ មកដល់បច្ចុប្បន្ននេះសំរាមបានកើនឡើងរហូតដល់១៣០០តោនក្នុងមួយថ្ងៃ ហើយទីលានចាក់សំរាមមួយត្រូវបានបិទលែងប្រើប្រាស់ ស្របពេលដែលទីលានចាក់សំរាមថ្មីមួយទៀត មានផ្ទៃដីជាង៣០ហត.ត្រូវបានបើកឲ្យប្រតិបត្តិការហើយវាមានគំរោងប្រើប្រាស់តែជាង ១០ ឆ្នាំប៉ុណ្ណោះ។ តាមរូបភាពនេះយ៉ាងយូរបំផុត ១០ ឆ្នាំទៀតរាជធានីភ្នំពេញត្រូវរកដីសំរាប់ធ្វើទីលានចាក់សំរាមថ្មីមួយទៀត។ ហើយយើងនឹងបន្តធ្វើរបៀបនេះគ្រប់ៗជំនាន់ យើងអាចស្រមៃឃើញថា ផ្ទៃដីរាជធានីភ្នំពេញទាំងមូលនឹង អាចក្លាយជាកន្លែងចាក់សំរាម សំណល់អាហារ និងសំណល់សំភារៈប្រើប្រាស់របស់អ្នកទីក្រុង ទាំងអស់ នាពេលអនាគត។ នេះគឺជាការនិទស្សន៍ សម្រាប់ទាក់ទាញការយកចិត្តទុកដាក់របស់ប្រជាពលរដ្ឋគ្រប់រូប បង្កើនការចូលរួមបង្កើតសំរាមកាន់តែតិច និងទុកដាក់សំរាមអោយបានត្រឹមត្រូវ។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី និងសិស្សានុសិស្សជាទីមេត្រី**!

ជាថ្មីម្តងទៀត ខ្ញុំសូមសំដែងនូវទឹកចិត្តសប្បាយរីករាយ ដែលបានចូលរួមជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ ក្នុងឱកាសមីទ្ទីញអបអរសាទរទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក០៥ មិថុនា២០១៣ នាពេលនេះ។ ខ្ញុំមានជំនឿថា ស្មារតីនៃការប្រារព្ធពិធីថ្ងៃនេះ នឹងប្រែក្លាយទៅជាសកម្មភាពជាក់ស្តែង ចូលរួមក្នុងការសន្សំសំចៃចំណីអាហារ មិនអោយមានសំណល់ ថែរក្សាសោភ័ណភាពទីក្រុង និងលើកកំពស់សុខដុមនីយកម្មបរិស្ថាន អោយបានសក្តិសមជា **រាជធានីស្រស់ស្អាតជាបេះដូង និងជាមជ្ឈមណ្ឌលនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ នៃព្រះរាជាណាចក្រកម្ពុជា**

ក្នុងនាមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ខ្ញុំសូមប្រកាសជាឱឡារឹកគាំទ្រនូវយុទ្ធនាការនេះ និងសូមអំពាវនាវដល់គ្រប់ផ្នែក គ្រប់ថ្នាក់ដែលប្រតិបត្តិផ្ទាល់នឹងសេវាផ្គត់ផ្គង់ចំណីអាហារ ក៏ដូចជាអ្នកទទួលទានអាហារគ្រប់រូប និងសិស្សានុសិស្សផងដែរ សូមចាប់ផ្តើមពីពេលនេះតទៅ ធ្វើការសន្សំសំចៃអាហារដែលទទួលទានរាល់ថ្ងៃ កុំអោយមានសំណល់ និយាយមួយបែបទៀតគឺគ្រប់ពេលវេលានៃការពិសារអាហារសូមពិសារអោយអស់ពីចាន។

ជាទីបញ្ចប់ ខ្ញុំ ព្រះករុណាខ្ញុំសូមប្រគេនពរនិងសូមជូនពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសិស្សានុសិស្ស ដែលមានវត្តមាននៅទីនេះទាំងអស់សូមជួបប្រទះ តែនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និង ពលៈកុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរព្រះគុណ និងសូមអរគុណ**!